ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ១៨៥/១៦ - តុង ឆៃ ហ្វេស្សិន គិចតូលូជី អិលធីឌី**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ហែម ហួណារិទ្ធ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន តុង ឆៃ ហ្វេស្សិន គិចតូលូជី អិលធីឌី**

អាសយដ្ឋាន ៖ ភូមិព្រៃបឹង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៩៨ ៥៥៣ ២១៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖ អវត្តមាន ។

**២- ភាគីកម្មករនិយោជិត**

**តំណាងកម្មករនិយោជិត នៃក្រុមហ៊ុន តុង ឆៃ ហ្វេស្សិន គិចតូលូជី អិលធីឌី**

អាសយដ្ឋាន ៖ ភូមិព្រៃបឹង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១១ ៧២៩ ៩៦៣ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិត ៖

- លោក ទូច ចាន់ណារិទ្ធ ប្រតិភូបុគ្គលិក និងជាប្រធានក្រុម

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីកម្មករ លោក ទូច ចាន់ណារិទ្ធ ជាប្រតិភូបុគ្គលិក ទាមទារចូលធ្វើការងារវិញជាធម្មតា ។ ភាគីក្រុមហ៊ុន មិនឯកភាព ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២២ កប/ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ (អាណត្តិទី១៤)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន តុង ឆៃ ហ្វេស្សិន តិចតូលូជី អិលធីឌី លេខ ១២៨៨/១៦ កប/កណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់តំណាងកម្មករនិយោជិត ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការទាមទារចូលធ្វើការវិញជាធម្មតា។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ និងធ្វើការផ្សះផ្សាវិវាទចំនួន ០១ ចំណុច នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន តុងឆៃ ខូអិលធីឌី លេខ ១២៨៨/១៦ កប/កណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សា លើករណីមិនសះជាចំនួន ០១ ចំណុច នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីកម្មករនិយោជិតមានវត្តមាននៅក្នុងសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំណែកឯភាគីនិយោជកមិនបានចូលរួមសវនាការ មិនមានវត្តមានក្នុងសវនាការទេ។

ARBITRATION COUNCIL

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញលិខិតអញ្ជើញជូននិយោជក ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាល តាមរយៈលិខិតអញ្ជើញលេខ ៩៧២ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ដោយមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការនាថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ នៅថ្ងៃសវនាការ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទាក់ទងទៅភាគីនិយោជកតាមទូរស័ព្ទបន្ថែមទៀត ប៉ុន្តែ ប្រធានរដ្ឋបាលរបស់ក្រុមហ៊ុនបានឆ្លើយតបថា សុំពន្យាពេលទៅពេលក្រោយវិញ ដោយមិនបានផ្តល់ហេតុផលត្រឹមត្រូវនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទនេះពីភាគីកម្មករនិយោជិត និងធ្វើការពិចារណាចំណុចវិវាទចំនួន ០១ ចំណុចនេះ។

សេចក្តីបង្គាប់នៅក្នុងសំណុំរឿងនេះ ជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវចេញនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន តុង ឆៃ ហ្វេស្សិន តិចណូឡូជី អិលធីឌី បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លេខ ៣០០/១៥ ក.ប.វ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។

២- តារាងប្រាក់ខែអ្នកលាលែង និងកាត និងតារាងបើកប្រាក់បំណាច់ឆ្នាំ របស់ ទូច ចាន់ណារិទ្ធ។

៣- លិខិតរបស់ក្រុមហ៊ុន តុង ឆាយ ហ្វេស្សិន តិចនូលូជី គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។

៤- វិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល នៃក្រុមហ៊ុន Tung Choi Fashion Technology លេខ ១៣៧ ឧស.ចប ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤។

៥- តារាងកត់ត្រាអ្នកប្រុងលាឈប់ ថ្ងៃស្នើសុំថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦។

៦- ពាក្យស្នើសុំធ្វើការងាររបស់ឈ្មោះ ទូច ចាន់ណារិទ្ធ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤។

៧- កិច្ចសន្យាការងារមានថេរៈវេលាកំណត់រវាងឈ្មោះ ទូច ចាន់ណារិទ្ធ និងក្រុមហ៊ុន គុង ឆាយ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- សារណាសង្ខេបវិវាទការងារក្រុមហ៊ុន បោះពុម្ព គាង ឆាយ របស់ឈ្មោះ ទូច ចាន់ណារិទ្ធ ជាប្រតិភូបុគ្គលិក និងជាប្រធានក្រុម គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦។

២- កិច្ចសន្យាការងារមានថេរៈវេលាកំណត់រវាងឈ្មោះ ទូច ចាន់ណារិទ្ធ និងក្រុមហ៊ុន គុង ឆាយ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦។

៣- សារណាជំទាស់សង្ខេបវិវាទការងារក្រុមហ៊ុន បោះពុម្ព គាង ឆាយ របស់លោក ទូច ចាន់ណារិទ្ធ ជាប្រតិភូបុគ្គលិក និងជាប្រធានក្រុម គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន បោះពុម្ព គុង ឆាយ លេខ ១២៨៨/១៦ ក.ប/កណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បោះពុម្ព គុង ឆាយ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៩៧២ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៩៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន គុងនៃ ខូអិលធីឌី គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការបោះពុម្ពសម្លៀកបំពាក់ និង ទទួលវិញ្ញាបនប័ត្រអនុញ្ញាតដំណើរការសិប្បកម្ម ចុះបញ្ជីក្រោមលេខ ៣២២០ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ

២០១៤។ បច្ចុប្បន្នក្រុមហ៊ុននេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ១២០ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន តុងឆៃ ខូអិលធីឌី)*។

- កម្មករនិយោជិត ទូច ចាន់ណារិទ្ធ ដែលជាប្រតិភូបុគ្គលិក មានវត្តមាននៅក្នុងសវនាការ និងជាកម្មករនិយោជិតតែម្នាក់គត់ដែលពាក់ព័ន្ធនឹងចំណុចវិវាទក្នុងសំណុំរឿងនេះ។

**ចំណុចវិវាទ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក ទទួលយកកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ឱ្យចូលធ្វើការវិញជាធម្មតា***

- យោងតាមការលើកឡើងរបស់ភាគីកម្មករនិយោជិត និងសារណារបស់ភាគីនិយោជក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ភាគីទាំងពីរឯកភាពថា ៖
  - កម្មករនិយោជិត ទូច ចាន់ណារិទ្ធ បានចាប់ផ្តើមចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុន នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ហើយមានមុខងារជាប្រធានផ្នែកអ៊ុត និងបោះពុម្ពរូបភាព ដោយមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ០៣ ខែម្តងៗ។ កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ០៣ ខែ ចុងក្រោយរបស់គាត់ គឺចាប់ផ្តើមពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ និងត្រូវបញ្ចប់នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។
  - និយោជកបានជូនដំណឹងបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់គាត់នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ ដែលនឹងត្រូវផុតកំណត់នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។ កម្មករនិយោជិត ទូច ចាន់ណារិទ្ធ បានបន្តធ្វើការងាររហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ តាមកិច្ចសន្យាការងាររបស់គាត់។
  - កម្មករនិយោជិត ទូច ចាន់ណារិទ្ធ បានជាប់ជាប្រតិភូបុគ្គលិកនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤ និងត្រូវផុតអាណត្តិនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦។
- ភាគីកម្មករនិយោជិតបានលើកឡើងពីមូលហេតុនៃការទាមទារថា និយោជកបានបញ្ឈប់កម្មករនិយោជិត ទូច ចាន់ណារិទ្ធិ ដោយមិនមានមូលហេតុសមស្រប ហើយការបញ្ឈប់នេះ គឺមកពីមូលហេតុនៃការរើសអើង កុំគួនមិនពេញចិត្តគាត់ដែលជាប្រតិភូបុគ្គលិក។ ក្រុមហ៊ុននៅមានការងារធ្វើ ហេតុនេះ និយោជកមិនត្រូវបញ្ឈប់កម្មករនិយោជិតដែលជាប្រតិភូបុគ្គលិកទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ៖
  - សព្វថ្ងៃនៅក្នុងក្រុមហ៊ុនមានប្រតិភូបុគ្គលិកពេញសិទ្ធិចំនួន ០២ នាក់ រួមទាំងគាត់។ ប្រហែលជានៅខែឧសភា ឆ្នាំ២០១៦ រដ្ឋបាលក្រុមហ៊ុនបានប្រាប់គាត់ថា ក្រុមហ៊ុនលែងតម្រូវឱ្យមានប្រតិភូបុគ្គលិកទៀតហើយ។ ដោយបានឮបែបនេះ គាត់បានប្រាប់ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ហើយនៅខែមិថុនា ឆ្នាំ២០១៦ មន្ត្រីរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចុះទៅក្រុមហ៊ុន ហើយធ្វើការពន្យល់ប្រាប់ទាក់ទងនឹងតួនាទីរបស់ប្រតិភូបុគ្គលិកថាក្រុមហ៊ុនមិនអាចអត់មានប្រតិភូបុគ្គលិកបានទេ។ និយោជកក៏បានទទួលយកអនុសាសន៍ ហើយ

បន្តឱ្យមានប្រតិភូបុគ្គលិក តែក្រុមហ៊ុន តុង រ៉ៃ នៅតែមិនបន្តកិច្ចសន្យាការងារជាមួយ លោក ទូច ចាន់ណារិទ្ធ ដដែល ។

- ការដែលនិយោជកមិនបន្តកិច្ចសន្យាការងារ គឺដោយសារនិយោជកមានការរើសអើង ខឹង គុំគួន ដែលកម្មករនិយោជិត ទូច ចាន់ណារិទ្ធ បាននាំព័ត៌មាននេះទៅដល់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលភ្លាមៗ ដើម្បីទាមទារការអន្តរាគមន៍ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ គាត់បានបន្តថា នេះជាហេតុផលដែលធ្វើអោយភាគីនិយោជកមិនពេញចិត្ត ដោយគិតថាគ្រាន់តែបញ្ហាតិចតួចសោះ ត្រូវហៅ ភាគីទី ០៣ អោយមកដល់ក្រុមហ៊ុន ។
- នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ បុគ្គលិកផ្នែករដ្ឋបាល បានប្រាប់គាត់ថា កិច្ចសន្យាការងាររបស់គាត់ត្រូវបានបញ្ចប់ហើយ គាត់អាចឈប់មកធ្វើការចាប់ពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ នេះតែម្តង ឬមកធ្វើការរហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ក៏បាន ។ ជាក់ស្តែងគាត់ទៅធ្វើការរហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ។
- ល្ងាចថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ កម្មករនិយោជិត ទូច ចាន់ណារិទ្ធ បានទូរស័ព្ទទៅផ្នែករដ្ឋបាលប្រចាំក្រុមហ៊ុន ហើយក៏បានបង្ហាញនូវឆន្ទៈ សុំបន្តកិច្ចសន្យា និងធ្វើការនៅក្រុមហ៊ុនបន្តទៀត ក៏ប៉ុន្តែ បុគ្គលិកផ្នែករដ្ឋបាលបានបញ្ជាក់ថា ក្រុមហ៊ុនមិនបន្តកិច្ចសន្យាជាមួយគាត់ទៀតទេ ព្រោះការងារផ្នែកអ៊ុតមិនសូវរវល់ដូចពីមុនទេ ។ កម្មករនិយោជិត ទូច ចាន់ណារិទ្ធ ក៏បានឆ្លើយតបទៅវិញថា គាត់មិនយល់ព្រមទេ ហើយគាត់នឹងជំរាបជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលពីបញ្ហានេះ ។
- កម្មករនិយោជិត ទូច ចាន់ណារិទ្ធិ បានបើកប្រាក់ឈ្នួល ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ និងប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៦ ។
- ចំពោះប្រតិភូបុគ្គលិកម្នាក់ទៀត គឺនៅបន្តធ្វើការនៅក្នុងក្រុមហ៊ុនដដែល ។

- យោងតាមសារណោរបស់ភាគីនិយោជក និយោជកបានលើកឡើងថា និយោជកបានបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ទូច ចាន់ណារិទ្ធ ដោយមូលហេតុថា ផ្នែកអ៊ុត និងបោះពុម្ព ដែលគាត់ធ្វើការនោះ គឺមិនមានការងារធ្វើជាច្រើនខែ ទើបនិយោជកសម្រេចរំសាយក្រុមនោះទាំងមូល ដែលរួមមានទាំងកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ដែលជាប្រធានមួយរូបផងដែរ ។

## ហេតុផលនៃសេចក្តីសម្រេច ៖

មុននឹងពិចារណាចំណុចទាមទារក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយអំពីនីតិវិធីអាជ្ញាកណ្តាលនៅពេលអវត្តមានភាគីនិយោជក ជាមុនសិន ៖

នៅថ្ងៃសវនាការ ភាគីនិយោជកមិនមានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើសវនាការដោយកំបាំងមុខភាគីនិយោជកដែរ ឬទេ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់"* ។

ទាក់ទងនឹងខ្លឹមសារនៃប្រការ២១ នៃប្រកាសលេខ ០៩៩ នៅក្នុងសំណុំរឿងមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅ ចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគីនិយោជក ដែលអវត្តមាននោះបាន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤-តួង ហុង, លេខ ៦៣/០៤-សាញ វ៉ែល, លេខ ១៤៨/០៧-ប៉ាយ ហី, លេខ ៩៩/០៩-យីង ឡែន, លេខ ១៧៣/១១-ជិន អ៊ីង, លេខ ១៤២/១២-អប្សរា, លេខ ១០៩/១៣-វិទ្យាស្ថាន ប៊ុណ្ណា កម្ពុជា, លេខ ១៦៣/១៤-ស៊ុន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ ២៥០/១៥-អិល អិល អេស ព្រីនធីង លេខ ០២២/១៦-អាត់តាឌីស (ខេមបូឌា) ហ្គាមេន និង លេខ ១២៨/១៦-សេង ហុង យាន អ៊ីមប្រយឌើរី ខូអិលធីឌី)* ។

នៅក្នុងសំណុំរឿងនេះ នៅថ្ងៃសវនាការមានតែភាគីកម្មករនិយោជិតទេ ដែលបានចូលរួមសវនាការតាមការអញ្ជើញ។

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញលិខិតអញ្ជើញជូននិយោជក ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាល តាមរយៈលិខិតអញ្ជើញលេខ ៩៧២ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ដោយមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការនាថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ នៅថ្ងៃសវនាការ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទាក់ទងទៅភាគីនិយោជកតាមទូរស័ព្ទបន្ថែមទៀត ប៉ុន្តែ ប្រធានរដ្ឋបាលរបស់ក្រុមហ៊ុនបានឆ្លើយតបថា សុំពន្យាពេលទៅពេលរសៀលវិញ ដោយមិនបានផ្តល់ហេតុផលត្រឹមត្រូវនោះទេ។

យោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ ខាងលើ ភាគីនិយោជកបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនិយោជកអវត្តមានបាន។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបន្តដំណើរការរបស់ខ្លួន ដោយអវត្តមានរបស់ភាគីនិយោជក និងចំពោះមុខភាគីកម្មករនិយោជិត ដើម្បីវិនិច្ឆ័យលើសំណុំរឿង ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ដោយផ្អែកលើភស្តុតាង និងការបកស្រាយបំភ្លឺរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ។

ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក ទទួលយកកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ឱ្យចូលធ្វើការវិញជាធម្មតា

យោងតាមអង្គហេតុ កម្មករនិយោជិត ទូច ចាន់ណារិទ្ធ បានចាប់ផ្តើមចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុន នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ និងមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ០៣ ខែចុងក្រោយ ចាប់ផ្តើមពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ និងត្រូវបញ្ចប់នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។ និយោជកបានជូនដំណឹងបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់គាត់នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ ដែលនឹងត្រូវផុតកំណត់នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។ កម្មករនិយោជិត ទូច ចាន់ណារិទ្ធ បានបន្តធ្វើការងាររហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ តាមកិច្ចសន្យាការងាររបស់គាត់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចក្នុងការទទួលកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ចូលធ្វើការវិញជាធម្មតាដែរ ឬ ទេ?

កថាខណ្ឌទី១ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ចែងថា *"កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ត្រូវផុតរលត់តាមធម្មតានៅពេលដល់កាលកំណត់ ។... ។"*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ការផុតរលត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាធ្វើឱ្យទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជក ត្រូវផុតរលត់ដោយស្វ័យប្រវត្តិ ហើយការសម្រេចចិត្តបន្តកិច្ចសន្យាសារជាថ្មីទៀត ឬ មិនបន្តនោះ ជាសិទ្ធិរបស់ភាគីនៃកិច្ចសន្យា ព្រោះកិច្ចសន្យា គឺជាការព្រមព្រៀងរវាងភាគី ដែលមិនមានភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០០/០៧-ហ្សូយ៉ៅ ខេមបូឌា និង លេខ ៦៤/០៩-ស៊ីណូមេក ២ , លេខ ០៩៨/១៤-វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី ហេតុផលនៃចំណុចវិវាទទី០១, លេខ ១៧២/១៤-ហ៊្វូត ហ្វ័រវើត (ខេមបូឌា) សកន៍ ខូ អិលធីឌី, ហេតុផលនៃចំណុចវិវាទទី១, លេខ ១៧៨/១៤-សួនឧស្សាហកម្ម មេនហាតធេន ហេតុផលនៃចំណុចវិវាទទី០១, លេខ ០០២/១៦-ត័ន ថេក (ខេមបូឌា) ខបភើរេសិន លីមីធីត ហេតុផលនៃចំណុចវិវាទទី១០ និងទី១១ និង លេខ ១០៥/១៦-ស៊ាវគិញ ហ្គាមេន (អ៊ីមអេហ្វជី) អិលធីឌី ហេតុផលនៃចំណុចវិវាទទី១០*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

យោងតាមអង្គហេតុ កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចុងក្រោយរបស់កម្មករនិយោជិត ទូច ចាន់ណារិទ្ធ ត្រូវដល់ពេលកំណត់ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ហើយកម្មករនិយោជិតរូបនេះបន្តធ្វើការរហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ករណីនេះ គឺជាការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ដែលជាហេតុធ្វើឱ្យទំនាក់ទំនងការងាររវាងកម្មករនិយោជិត ទូច ចាន់ណារិទ្ធ និងនិយោជកផុតរលត់ជាស្វ័យប្រវត្តិ ហើយការសម្រេចចិត្តបន្តកិច្ចសន្យាថ្មី ឬមិនបន្ត គឺជាសិទ្ធិរបស់ភាគីនៃកិច្ចសន្យា ហើយក៏គ្មានភាគីណាមួយ អាចបង្ខំឱ្យភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ បើគ្មានការព្រមព្រៀង។

ARBITRATION COUNCIL

ដោយឡែក យោងតាមអង្គហេតុ កម្មករនិយោជិត ទូច ចាន់ណារិទ្ធ ជាប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើសិទ្ធិទទួលបានការការពារ ពីការបញ្ឈប់ពីការងារអនុវត្តចំពោះករណីមិនបន្តកិច្ចសន្យាការងារដែរ ឬទេ?

មាត្រា ៤៣ នៃច្បាប់ស្ដីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា “*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ។...*”

យោងតាមមាត្រា ៤៣ នៃច្បាប់ស្ដីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការការពារពិសេស កើតមានតែចំពោះករណីបញ្ឈប់ពីការងារប៉ុណ្ណោះ ដែលច្បាប់តម្រូវឱ្យនិយោជកសុំការអនុញ្ញាតពីអធិការការងារ។

យោងតាមការបកស្រាយខាងលើ ករណីកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ជាករណីមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ហេតុនេះ ការការពារពិសេស តាមមាត្រា ៤៣ នៃច្បាប់ស្ដីពីសហជីពខាងលើ មិនអាចយកមកអនុវត្តបានទេ។

យ៉ាងណាមិញ នៅក្នុងសំណុំរឿងលេខ៦៤/០៩-ស៊ីណូមេក ២ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយថា៖ “*ភាគីនិយោជកមានសិទ្ធិក្នុងការសម្រេចមិនបន្តកិច្ចសន្យាការងារនៅពេលកិច្ចសន្យានោះ ដល់ថិរវេលាកំណត់ លើកលែងតែនិយោជកយកមូលហេតុនៃការរើសអើង ធ្វើជាមូលដ្ឋាននៃការសម្រេចចិត្តក្នុងការមិនបន្តកិច្ចសន្យា*”។ (*សូមមើលបន្ថែមសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ១៧២/១៤-ហ៊្វូត ហ្វ័រវើត (ខេមបូឌា) សកទី ខូ អិលធីឌី ហេតុផលនៃចំណុចវិវាទទី០១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្តពិចារណាថា តើការមិនបន្តកិច្ចសន្យាការងារ ដែលមានកំណត់របស់កម្មករនិយោជិត ទូច ចាន់ណារិទ្ធ មានពាក់ព័ន្ធនឹងការរើសអើង ដែរ ឬទេ?

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការបកស្រាយយ៉ាងស៊ីសង្វាក់គ្នាថា “*ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថា ភាគីដែលធ្វើការចោទប្រកាន់មានបន្ទុកភស្តុតាង ក្នុងការបង្ហាញមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីគាំទ្រការចោទប្រកាន់ដែលបានលើកឡើង*”។ (*សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ១៤៨/០៧-ប៉ាយ ហ៊ី, លេខ ៣៨/១១-លីម ឡាញ ហេតុផលនៃចំណុចវិវាទទី៧, លេខ ១៥៥/១១-យឹងដុង ហេតុផលនៃចំណុចវិវាទទី១, លេខ ១៨១/១៤-ស្បុង យិន (ខេមបូឌា) ប៊ី ឌិកស្គាយ៍ ហេតុផលនៃចំណុចវិវាទទី៦, លេខ ០០២/១៥-ក័រហ្វិក គ្រោស៍ ប្រាយវេត ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី០២ និងលេខ ១០៩/១៥-ហុង ស៊ុន ហ្គាមេន (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី០១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ។

ទាក់ទងនឹងភស្តុតាងនៃការរើសអើង ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ពន្ធ័ទៅនឹងសំណុំរឿង ដើម្បីកំណត់ថាមានការរើសអើងកើតមានឡើងដែរ ឬ ទេ។

យោងតាមការលើកឡើង ភាគីកម្មករនិយោជិតបានអះអាងថា និយោជកបានផ្តាច់កិច្ចសន្យាការងារដោយមូលហេតុនៃការរើសអើង គុំគួន មិនពេញចិត្តគាត់ដែលជាប្រតិភូបុគ្គលិក។ ជាក់ស្តែង គឺ ប្រហែលជានៅខែឧសភា ឆ្នាំ២០១៦ បន្ទាប់ពីបានឮរដ្ឋបាលថា ក្រុមហ៊ុនលែងតម្រូវឱ្យមានប្រតិភូបុគ្គលិកទៀតហើយ គាត់បានប្រាប់ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ហើយនៅខែមិថុនា ឆ្នាំ២០១៦ មន្ត្រីរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចុះទៅក្រុមហ៊ុន ហើយធ្វើការពន្យល់ប្រាប់ទាក់ទងនឹងតួនាទីរបស់ប្រតិភូបុគ្គលិក ហើយថា ក្រុមហ៊ុនមិនអាចអត់មានប្រតិភូបុគ្គលិកបានទេ។ ហេតុនេះ ទើបនិយោជកមិនពេញចិត្តនឹងគាត់ ដោយគិតថា គ្រាន់តែបញ្ហាតិចតួចសោះ ត្រូវហៅភាគីទី០៣ អោយមកដល់ក្រុមហ៊ុនដោះស្រាយ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតមានបន្ទុកភស្តុតាងក្នុងការបង្ហាញ ថាការដែលនិយោជកមិនបន្តកិច្ចសន្យាការងាររបស់គាត់ដោយមូលហេតុនៃការរើសអើង ដោយគាត់ជាប្រតិភូបុគ្គលិក ហើយនិយោជកមានការគុំគួននឹងការដែលគាត់បានប្រាប់ឱ្យមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាវៈខេត្តកណ្តាលចុះមកធ្វើអន្តរាគមន៍ នៅខែមិថុនា ឆ្នាំ២០១៦ ដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីធ្វើជាមូលដ្ឋានក្នុងការពិចារណា។ ដោយឡែក ក្រៅពីអំណះ-អំណាងខាងលើ ភាគីកម្មករនិយោជិតមិនបានផ្តល់បន្ទុកភស្តុតាងគាំទ្រណាមួយ ដើម្បីអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿបានថា និយោជកមិនបន្តកិច្ចសន្យាការងាររបស់គាត់ដោយមូលហេតុគុំគួន ដូចគាត់លើកឡើងនោះទេ។ មិនតែប៉ុណ្ណោះ ភាគីកម្មករនិយោជិតផ្ទាល់ក៏បានលើកឡើងដែរថា សព្វថ្ងៃប្រតិភូបុគ្គលិកម្នាក់ទៀតនៅក្នុងក្រុមហ៊ុន គឺនៅបន្តធ្វើការដដែល។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញអង្គហេតុណាមួយ ដែលអាចធ្វើការសន្និដ្ឋានបានថា និយោជកមានការរើសអើងប្រតិភូបុគ្គលិក មានបំណងលុបបំបាត់មិនឱ្យមានប្រតិភូបុគ្គលិក ទើបនិយោជកមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិត ទូច ចាន់ណារិទ្ធិ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលច្រានចោលនូវការលើកឡើងរបស់ភាគីកម្មករនិយោជិតអំពីមូលហេតុដែលបានលើកឡើងខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ចូលធ្វើការនៅកន្លែងដើមវិញ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទ ៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលកម្មករនិយោជិត ទូច ចាន់ណារិទ្ធ ចូលធ្វើការនៅកន្លែងដើមវិញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ហែម ហួណារិទ្ធ**

ហត្ថលេខា ៖ ---------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន ធីរៈ**

ហត្ថលេខា ៖---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា ៖ ---------------------------------